ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៥៨០៥ សហវ.ទសអ

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៧

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ:** ករណីសំណើសុំពិនិត្យនិងសម្រេចប្រគល់កិច្ចសន្យាជូន **ក្រុមហ៊ុនហ្គ្រីន សេវេន ស៊ីដ** ស្តីពីការផ្គត់ផ្គង់ថ្នាំចាក់ការពារ ព្យាបាលសត្វនិង សម្ភារបរិក្ខារបសុពេទ្យប្រចាំឆមាសទី១ឆ្នាំ២០១៧ ជូនអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។

**យោង:** -លិខិតលេខ ៣៥៨១សហវ.អថចុះថ្ងៃទី០២ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-កំណត់ហេតុបើកឯកសារដេញថ្លៃចុះថ្ងៃទី១៣ខែកក្កដា ឆ្នាំ២០១៧ និងកំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា ចុះថ្ងៃទី១៨ខែកក្កដា ឆ្នាំ២០១៧របស់គ.លក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
-លិខិតលេខ ៦៤៥៩ កសក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការប្រគល់កិច្ចសន្យាជូន **ក្រុមហ៊ុន ហ្គ្រីន សេវេន ស៊ីដ** ដើម្បីផ្គត់ផ្គង់ថ្នាំចាក់ការពារ ព្យាបាលសត្វ និងសម្ភារបរិក្ខារបសុពេទ្យប្រចាំឆមាសទី១ឆ្នាំ២០១៧ ក្នុងតម្លៃទឹកប្រាក់សរុបចំនួន ១.៩៩៩.៧០៦.០០០រៀល (មួយប៊ីលាន ប្រាំបួនរយកៅសិបប្រាំបួនលាន ប្រាំពីររយប្រាំមួយពាន់រៀលគត់ ) ជាតម្លៃកិច្ចសន្យា ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាប និងមានវិធានការអនុវត្តបន្តឱ្យបានសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

ក.ទេសរដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**រដ្ឋលេខាធិការ**

ហត្ថលេខា

ឡុង វិជិត្រ

ចម្លងជូន
-អគ្គនាយកដ្ឋានថវិកា
-អគ្គនាយកដ្ឋានពន្ធដារ
-ក្រុមហ៊ុន ហ្គ្រីន សេវេន ស៊ីដ
-ឯកសារ-កាលប្បវត្តិ